# ឯកសារទស្សនទាន សម្រាប់សិក្ខាសាលាស្តីពី

## បរិយាកាសអំណោយផលសម្រាប់ការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ

### ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ នៅសណ្ឋាគារ ហ៊ីរ ប៊ុន្នី

## បុព្វកថា

ចាប់តាំងពីទសវត្សឆ្នាំ១៩៩០ ប្រទេសកម្ពុជាមានការវិវត្តយ៉ាងឆាប់រហ័ស បន្ទាប់ពីមានកំណែទម្រង់សេដ្ឋកិច្ច និងនយោបាយ។ ជាងនេះទៀត កំណែទម្រង់អភិបាលកិច្ច សម្រាប់អភិវឌ្ឍថ្នាក់ក្រោមជាតិចាប់តាំងពី ឆ្នាំ២០០២ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (D&D) តាមរយៈកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (ផអ៣-បច្ចុប្បន្នដំណាក់កាលទី២) ព្រមទាំងច្បាប់ស្តីពីការរៀបចំក្រុមប្រឹក្សាស្រុក/ខណ្ឌ ខេត្ត/ក្រុងជាដើម។

ក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនេះ ការងារវិមជ្ឈការសម្រាប់ការងារអភិវឌ្ឍន៍តាមរយៈក្រុមប្រឹក្សាឃុំ/សង្កាត់ ស្រុក/ខណ្ឌ មានតួនាទីយ៉ាងសំខាន់ សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តក្នុងតំបន់ ពិសេសក្នុងការទទួលខុសត្រូវសម្រាប់ការរៀបចំផែនការអភិវឌ្ឍ ការដោះស្រាយបញ្ហាក៏ដូចជាការទំនាក់ទំនងដ៏សំខាន់ជាមួយ តួអង្គអភិវឌ្ឍដទៃទៀត ដូចជាអង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតជាដើម។ម្យ៉ាងទៀត សង្គមស៊ីវិលក៏មានការរួមចំណែកសំខាន់ក្នុងដំណើរការអភិវឌ្ឍនេះដែរ។ ជាលទ្ធផលនៃការស្រាវជ្រាវកន្លងមកបានប៉ាន់ប្រមាណ មានអង្គការដៃគូចំនួន ១៣១៥ ដែលមានសកម្មភាព និងបានរួមចំណែកប្រមាណ ៦០០-៧០០ លានដុល្លារ ក្នុងឆ្នាំ ២០១២ និងការផ្តល់ការងារដោយផ្ទាល់ប្រមាណ ៤៣០០០នាក់ ធ្វើការឱ្យអ្នកទទួលផលចំនួនប្រមាណ ២០-៣០% នៃប្រជាជនកម្ពុជា។

ដើម្បីចូលរួមលើកកម្ពស់លើផ្នែកកិច្ចសហការ បង្កើតការចូលរួម និងទំនាក់ទំនងអោយកាន់តែប្រសើរបន្ថែមទៀតលើការងារអភិវឌ្ឍន៍តាមមូលដ្ឋាន អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដែលជាអង្គការសមាជិកភាពមានសមាជិកជាង១៦០ ដោយរួមសហការជាមួយបណ្តាញអង្គការមិនមែនរដ្ឋាភិបាលប្រចាំខេត្ត ក្រចេះ ខេត្តស្ទឹងត្រែង និងខេត្តរតនៈគីរី និងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី **បរិយាកាសអំណោយផលសម្រាប់ការអភិវឌ្ឍថ្នាក់ក្រោមជាតិ** ដែលនឹងប្រព្រឹត្តិទៅនា **ព្រឹកថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥** ដែលមានសមាសភាពសមាសភាពតំណាងអញ្ជើញចូលរួមពីអាជ្ញាធរថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍផ្សេងទៀត ដែលមានចំនួនសរុបប្រមាណជាង ៦០នាក់។

## គោលបំណងសិក្ខាសាលា

សិក្ខសាលានេះមានគោលបំណងដើម្បីៈ

- បង្កើនកិច្ចសហការ ពីតួអង្គផ្សេងៗសម្រាប់ការងារអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ
- ចែករំលែកលទ្ធផលបឋមនៃការសិក្សាស្រាវជ្រាវបរិយាកាសអំណោយសម្រាប់ អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ
- ចែករំលែកពីការចូលរួម និងតួនាទីសំខាន់ៗពីភាគីអភិឌ្ឍពាក់ព័ន្ធ និងស្វែងរកយុទ្ធសាស្រ្តសម្រាប់ចូលរួមអភិវឌ្ឍពីភាគីពាក់ព័ន្ធ អោយកាន់តែមានប្រសិទ្ធភាព

## សមាសភាពចូលរួម និងទីកន្លែង

សិក្ខាសាលានេះ នឹងរៀបចំឡើងនៅសណ្ឋាគារ ហ៊ែរ ប៊ុន្នី តាមបណ្តោយផ្លូវជាតិលេខ៧ ក្នុងទីខេត្តក្រចេះ (ទល់មុខកងរាជអាវុធហត្ថខេត្តក្រចេះ)។

សមាសភាពចូលរួមក្នុងសិក្ខាសាលាមានប្រមាណ៦០នាក់ ដែលអញ្ជើញចូលរួមជាតំណាងមកពីអាជ្ញាធរថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍មូលដ្ឋាន គណៈកម្មាធិការជាតិសម្រាប់ការអិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងវិស័យឯកជន ដែលអញ្ជើញមកពីខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងខេត្តរតនៈគីរី។

## របៀបវារៈ

| ពេលវេលា | កម្មវិធី | អ្នកសម្របសម្រួល |
|---|---|---|
| 7:30-8:00 | **ការចុះឈ្មោះចូលរួមភ្ញៀវកិត្តិយល និងគណៈអធិបតី** | បណ្តាញអង្គការខេត្ត ក្រចេះ និង អង្គការ CCC |
| 8:00-8:15 | **គោរពភ្លេងជាតិ និងគោលបំណងកម្មវិធី** | អ្នកកាន់កម្មវិធី |
| 8:15-8:30 | **កិច្ចស្វាគមន៍ និងសុន្ទរកថាបើកកម្មវិធីបើកកម្មវិធីៈ**<br>សុន្ទរកថាបើកកម្មវិធី និងគន្លឹះសំខាន់ៗរបស់ខេត្តសម្រាប់ការអភិវឌ្ឍក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល | -ឯកឧត្តមអភិបាលខេត្តក្រចេះ<br>……… (ទំនាក់ទំនងបន្ថែម) |
| 8:30-9:20 | **ការងារអភិវឌ្ឍថ្នាកក្រោមជាតិ និង បណ្តាញអង្គការមិនមែនរដ្ឋាភិបាលខេត្ត**<br>- ការងារអភិវឌ្ឍថ្នាក់ក្រោមជាតិ តាមបែបប្រជាធិបតេយ្យ ផអព ដំណាក់កាលទី២ និងកិច្ចសហការជាមួយសង្គមស៊ីវិល<br>- ការងារបណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្ត | - **លោក អ៊ុក ពិសិដ្ឋ**<br>តំណាងទីប្រឹក្សា គជអប ខេត្ត<br>**-លោក យស់ ភារី**<br>ប្រធានសម្របសម្រួលបណ្តាញអង្គការខេត្ត និងនាយក |

| ពេលវេលា | កម្មវិធី | អ្នកសម្របសម្រួល |
| --- | --- | --- |
| | - សំនួរ និងចម្លើយ | ប្រតិបត្តិអង្គការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ |
| 9:20-10:15 | **ទិដ្ឋភាពទូទៅសម្រាប់បរិយាកាសអំណោយផល និងបទបង្ហាញអំពីការរកឃើញបឋម៖**<br>- ទិដ្ឋភាពទូទៅសម្រាប់បរិយាកាសអំណោយផល<br><br>-បទបង្ហាញអំពីការរកឃើញបឋម<br>- បរិយាកាសអំណោយសង្គមស៊ីវិលខេត្តក្រចេះ<br>- បរិយាកាសអំណោយសង្គមស៊ីវិលខេត្តរតនៈគីរី<br>- បរិយាកាសអំណោយសង្គមស៊ីវិលខេត្តស្ទឹងត្រែង<br>- **សំនួរ និងចម្លើយ** | **-លោក ជេន សុជឿន**<br>អ្នកស្រាវជ្រាវ និងការងារសម្ព័ន្ធ អង្គការ CCC<br>**-លោក អ៊ុក យុទ្ធ**<br>សមាជិកបណ្តាញអង្គការខេត្ត និងនាយកប្រតិបត្តិ អង្គការ KAFDOC<br>**-លោក ផល ចាន់សត្យា**<br>ប្រធានសម្របសម្រួលបណ្តាញអង្គការខេត្ត និងអ្នកសម្របសម្រួលប្រចាំប្រទេសនៃមូលនិធិ ETEA<br>**-លោក គ្រី សុទ្ធឡានី**<br>ប្រធានសម្របសម្រួលបណ្តាញអង្គការខេត្តស្ទឹងត្រែង |
| 10:15- 10:30 | **សំរាកអាហារសំរ៉ន់** | អញ្ជើញចូលរួមទាំងអស់គ្នា |
| 10:30 - 11.45 | **ការពិគ្រោះយោបល់ជាក្រុមសម្រាប់ពង្រឹងកិច្ចសហការ និងចូលរួមការងារអភិវឌ្ឍអោយកាន់តែមានប្រសិទ្ធភាព** | **លោក មី ណាក់**<br>ប្រធានផ្នែក កសាងបណ្តាញ និងភាពជាដៃគូ អង្គការ CCC |
| 11:45-12:00am | **បិទកម្មវិធី** | **លោក យស់ ភារី**<br>ប្រធានសម្របសម្រួលបណ្តាញអង្គការខេត្ត និងនាយកប្រតិបត្តិអង្គការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ |

**សំគាល់៖** អ្នករៀបចំកម្មវិធីសូមរក្សាសិទ្ធិក្នុងការកែប្រែរបៀបវារៈក្នុងករណីចាំបាច់។